សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន
០៦ កញ្ញា ២០១៣

**សូមគោរព ឯកឧត្តម អ៊ុំ ភូមិរ៉ូ អគ្គនាយករងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា** (CMAC)!
**សូមគោរព លោក តាកាគូវ៉ា ហ្វូមីតូហ្ស៊ី ប្រធានតំណាងអង្គការសកម្មភាពកំចាត់មីនជប៉ុន** (JMAS)!
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខានៅថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយជាមួយ អង្គការសកម្មភាពកំចាត់មីនជប៉ុន(JMAS)សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនគឺ “គម្រោងបង្កើនប្រសិទ្ធភាពបោសសម្អាតមីនក្នុងខេត្តបាត់ដំបងឆ្នាំ២០១៣”។

ដូចដែលយើងទាំងអស់គ្នាបានដឹងហើយ ដោយសារសង្គ្រាមផ្ទៃក្នុងជាច្រើនឆ្នាំ កម្ពុជានៅមានមីនជាច្រើនដែលត្រូវបានកប់ចោលនៅក្នុងដី ពិសេសភាគពាយ័ព្យនៃប្រទេស។ វត្តមាននៃគ្រាប់មីន និងយុទ្ធភ័ណមិនទាន់ផ្ទុះគឺជាឧបសគ្គដ៏ធំមួយសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ហើយការដោះស្រាយបញ្ហាមីននេះគឺជាជំហ៊ានមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេដ្ឋកិច្ច ក៏ដូចជាវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទផងដែរ។

រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តឧបត្ថម្ភគាំទ្រដល់សកម្មភាពកំចាត់មីននៅកម្ពុជាតាមរយៈជំនួយឧបត្ថម្ភក៏ដូចជាកិច្ចសហប្រតិបត្តិការផ្ទេរបច្ចេកទេស។ យ៉ាងណាមិញ បើទោះជាចំនួនជនរងគ្រោះបានបន្តថយចុះ ក៏នៅតែមានប្រជាជនជិត២០០នាក់រងគ្រោះដោយសារគ្រាប់មីននិងយុទ្ធភ័ណមិនទាន់ផ្ទុះក្នុងឆ្នាំ២០១២ ជាពិសេសខេត្តបាត់ដំបងគឺជាតំបន់ដែលទទួលផលប៉ះពាល់ខ្លាំងជាងគេនោះមានជនរងគ្រោះច្រើនជាងមួយភាគបីនៃចំនួនជនរងគ្រោះទាំងអស់។ ដូច្នេះយើងនៅតែមានតំរូវការខ្ពស់សម្រាប់សកម្មភាពបោសសម្អាតមីនក្នុងខេត្តនេះ។

ស្ថិតក្រោមស្ថានភាពបែបនេះ អង្គការJMAS តាមរយៈជំនួយឧបត្ថម្ភផ្លូវការរបស់ជប៉ុនសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន បានសហការជាមួយCMACក្នុងកិច្ចបោសសម្អាតមីនដោយចាប់ផ្តើមក្នុងខេត្តព្រៃវែងក្នុងឆ្នាំ២០០២ និងពង្រីកគោលដៅរបស់ខ្លួនជាបន្តបន្ទាប់រហូតដល់១៣ខេត្តនាពេលបច្ចុប្បន្ននេះ។ រយៈពេល១០ឆ្នាំកន្លងមកនេះ អង្គការJMASបានបន្តធ្វើសកម្មភាពបោសសម្អាតមីន និងយុទ្ធភ័ណមិនទាន់ផ្ទុះ ក៏ដូចជាផ្ទេរបច្ចេកទេសជាច្រើនទៅដល់CMACដែលជាការចូលរួមចំណែកដ៏ធំធេងក្នុងការកសាងសន្តិភាពក្នុងប្រទេសកម្ពុជា។

ជាមួយនឹងជំនួយប្រមាណ ហុកសិបប្រាំលានយ៉េន ដែលរដ្ឋាភិបាលជប៉ុន ផ្តល់ដល់ អង្គការJMAS នៅថ្ងៃនេះ អង្គការJMASនឹងធ្វើសកម្មភាពបោសសម្អាតមីនក្នុងភូមិចំនួនបីនៃឃុំត្រែង និងភូមិមួយរបស់ឃុំរស្មីសង្ហារ ក្នុងស្រុករតនៈមណ្ឌលដែលត្រូវបានចាត់ទុកជាតំបន់ដែលទទួលរងគ្រោះធ្ងន់ធ្ងរដោយសារគ្រាប់មីនក្នុងខេត្តបាត់ដំបង។

ចាប់តាំងពីគម្រោងឆ្នាំមុន អង្គការJMASបាននិងកំពុងផ្ទេរបច្ចេកទេសថ្មីៗដល់CMAC ហើយពួកគេកំពុងធ្វើការបោសសម្អាតមីនស្របតាមវិធីសាស្រ្ត Land Release ដែលជាវិធីសាស្រ្តស្តង់ដារ របស់UN។ ដោយប្រើប្រាស់វិធីសាស្រ្តនេះ ពួកគេនឹងអាចធ្វើការបោសសម្អាតមីនបានឆាប់រហ័សជាងមុនដែលនឹងរួមចំណែកដល់ការសម្រេចតាមផែនការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកាបោសសម្អាតមីនត្រឹមឆ្នាំ២០១៩ដូចមានចែងក្នុងអនុសញ្ញាOtawa។

តាមរយៈគម្រោងនេះ ក្រៅពីបន្តផ្ទេរបច្ចេកទេសដល់CMAC ប្រជាពលរដ្ឋប្រមាណប្រាំមួយពាន់ប្រាំពីររយនាក់ក្នុងភូមិ៤នៃឃុំត្រែង និងឃុំរស្មីសង្ហា ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ក៏នឹងត្រូវបានរំដោះចេញពីការគំរាមកំហែង និងការភ័យខ្លាចដោយសារគ្រាប់មីន។ ខ្ញុំសង្ឃឹមថា គម្រោងនេះនឹងធ្វើឲ្យស្ថានភាពជីវិតរបស់ពួកគេមានលំនឹង ធ្វើឲ្យប្រសើរឡើងនូវបរិស្ថានរស់នៅ ក៏ដូចជាបន្តអភិវឌ្ឍន៍សហគមន៍ក្នុងតំបន់។

ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភរបស់ជប៉ុនសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានផ្តល់ជូនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលជប៉ុន។ ហើយខ្ញុំសូមធ្វើការកោតសរសើរ និងគោរពដោយស្មោះចំពោះអ្នកទាំងអស់គ្នាដែលបានរួមចំណែកក្នុងកិច្ចការបោសសម្អាតមីននៅកម្ពុជាដែលជាកិច្ចការដ៏លំបាក និងប្រឈមនឹងគ្រោះថ្នាក់មួយ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាកិច្ចសហប្រតិបត្តិការនេះនឹងមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជនក្នុងតំបន់ប៉ុណ្ណោះទេ ហើយក៏នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជាផងដែរ។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!